រាជបណ្ឌិត្យសភាកម្ពុជា
វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ
ផ្នែកបុរាណវត្ថុវិទ្យា

# ប្រាសាទត្រពាំងប្រាសាទ






ផុន កសិកា

ឆ្នាំ២០១០

**សមាសភាពមន្ត្រីសិក្សាស្រាវជ្រាវ៖**

លោក ផុន កសិកា

លោក ហឿង សុធារស់

លោក ជ័យ រតនា

លោក ឃិន សាវន់

**ចូលរួមសហការស្រាវជ្រាវ៖**

លោក ផុន ជាកុសល

លោក ជឿន សុខុន

លោក ឡេង សត្យា

លោក ឡេង វិទ្យា

លោក ឡេង វិទូ

## ទីប្រឹក្សាបច្ចេកទេស

១. លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

២. ឯកឧត្តម ជុច ភឿន  រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធានអាជ្ញាធរជាតិព្រះវិហារ និងជាទីប្រឹក្សាបច្ចេកទេសនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា។

៣. ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ។

៤. ឯកឧត្តមបណ្ឌិតរដ្ឋ តិច សំណាង ទីប្រឹក្សារាជរដ្ឋាភិបាល និងជាទីប្រឹក្សាបច្ចេកទេស នៃ វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា។

## គណៈកម្មការគ្រប់គ្រងគម្រោងស្រាវជ្រាវ

| | |
|---|---|
| ១. ឯកឧត្តមបណ្ឌិត នូ ចាន់សូភី | ប្រធាន |
| ២. ឯកឧត្តម លី សុធីរត្ន័ | សមាជិក |
| ៣. លោក ផុន កសិកា | សមាជិក |

**សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំជាមន្ត្រីស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះរាជបណ្ឌិត្យសភាកម្ពុជាដែលបានគាំទ្រ និងឧបត្ថម្ភថវិកាដល់គម្រោងស្រាវជ្រាវនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះមន្ត្រីបម្រើការក្នុងផ្នែករដ្ឋបាលនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានជួយសម្របសម្រួលរាល់លិខិតរដ្ឋបាលផ្សេងៗ ដើម្បីឲ្យគម្រោងនេះអាចដំណើរការបានតាមពេលវេលាកំណត់។ ឆ្លៀតឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលបានអនុញ្ញាត និងបញ្ជូនមន្ត្រីនៅមូលដ្ឋានចូលរួមសហការស្រាវជ្រាវ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអាជ្ញាធរដែនដីជួយសម្រួលរាល់លិខិតចុះសិក្សាស្រាវជ្រាវ មានកិច្ចសហការល្អជាមួយក្រុមការងារស្រាវជ្រាវ។។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់សមាជិកស្រាវជ្រាវ និងអស់លោកដែលបានចូលរួមសហការស្រាវជ្រាវទាំងអស់ បានចូលរួមសិក្សាស្រាវជ្រាវរហូតទទួលបានជោគជ័យ។

## មាតិកា


ទំព័រ

សេចក្តីថ្លែងអំណរគុណ.................................................... I

មាតិកា.................................................... II

បញ្ជីរូបភាព.................................................... V

បញ្ជីផែនទី និងប្លង់ប្រាសាទ.................................................... VIII

សេចក្តីផ្តើម.................................................... ១

គោលបំណងនិងអត្ថប្រយោជន៍នៃគម្រោង.................................................... ២

វិធីសាស្ត្រស្រាវជ្រាវ.................................................... ២

ជំពូកទី១៖ ប្រាសាទត្រពាំងប្រាសាទខាងត្បូង.................................................... ៤

១-កស៊ិណទឹក.................................................... ៦

២-កំពែងនិងខ្លោងទ្វារ.................................................... ៧

៣-ខឿនប្រាសាទ.................................................... ៧

៤-ប្រាង្គនៃប្រាសាទ.................................................... ៨

៤-ក. ប្រាង្គកណ្តាល.................................................... ៨

៤-ខ. ប្រាង្គខាងត្បូង.................................................... ១០

៤-គ. ប្រាង្គខាងជើង.................................................... ១២

៥-ហោជាង.................................................... ១៣

៦-សសរស្តម្ភ.................................................... ១៤

៧-សសរផ្អោប.................................................... ១៦

៨-ផ្តែរ.................................................... ១៦

៩-លិង្គ.................................................... ១៧

ជំពូក២៖ ប្រាសាទត្រពាំងប្រាសាទខាងជើង.................................................... ១៩

១-កំពែងនិងខ្លោងទ្វារ.................................................... ១៩

២-ប្រាង្គប្រាសាទ.................................................... ២០

**៣-ហោត្រៃ**............................................................................................... ២១

**ជំពូកទី៣៖ ការកំណត់អាយុកាលនៃប្រាសាទត្រពាំងប្រាសាទ**................................................ ២៣

**សន្និដ្ឋាន**.................................................................................................................... ២៧

**ឯកសារពិគ្រោះ**............................................................................................................ ២៨

## បញ្ជីរូបភាព

រូបលេខ១៖ កស្សិណទឹកប្រាសាទខាងត្បូង ជ្រុងឦសាន........ ៦
រូបលេខ២៖ កំពែងប្រាសាទខាងត្បូង ជ្រុងឦសាន........ ៧
រូបលេខ៣៖ ទិដ្ឋភាពខឿនប្រាសាទខាងត្បូង នៅទិសខាងកើត........ ៨
រូបលេខ៤៖ ប្រាង្គកណ្តាលនៃប្រាសាទខាងត្បូង........ ៩
រូបលេខ៥៖ ប្រាង្គខាងត្បូងនៃប្រាសាទខាងត្បូង........ ១១
រូបលេខ៦៖ ប្រាង្គខាងជើងនៃប្រាសាទខាងត្បូង........ ១៣
រូបលេខ៧ និង៨៖ បំណែកហោជាងប្រាសាទខាងត្បូង........ ១៤
រូបលេខ៩៖ សសរស្តម្ភប្រាសាទខាងត្បូង........ ១៥
រូបលេខ១០៖ សសរស្តម្ភប្រាសាទខាងត្បូង........ ១៥
រូបលេខ១១៖ សសរផ្តោបនៃប្រាង្គខាងជើង របស់ប្រាសាទខាងត្បូង សាងពីថ្មភក់ នៅបន្តពីសសរស្តម្ភ........ ១៦
រូបលេខ១២៖ បំណែកផ្តែរពីរផ្ទាំងផ្គុំគ្នា ស្ថិតក្នុងបរិវេណប្រាសាទខាងត្បូង........ ១៧
រូបលេខ១៣៖ លិង្គនៅក្នុងបរិវេណប្រាសាទខាងត្បូង........ ១៧
រូបលេខ១៤៖ ទិដ្ឋភាពប្រាសាទត្រពាំងប្រាសាទខាងត្បូង មើលពីទិសនិរតី........ ១៨
រូបលេខ១៥៖ ខ្លោងទ្វារខាងកើតនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម........ ២០
រូបលេខ១៦៖ ប្រាង្គកណ្តាលនៃប្រាសាទខាងជើង មើលពីទិសខាងកើត សង់ពីថ្មបាយក្រៀម........ ២០
រូបលេខ១៧៖ ហោត្រៃប្រាសាទខាងជើង........ ២១

## បញ្ជីផែនទី និងប្លង់ប្រាសាទ

ផែនទីលេខ១៖ ផែនទីបង្ហាញទីតាំងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ........ ៣
ផែនទីលេខ២៖ ទីតាំងប្លង់ស្រុកត្រពាំងប្រាសាទ........ ៤
ផែនទីលេខ៣៖ ប្លង់បាតប្រាសាទត្រពាំងប្រាសាទខាងត្បូង........ ៥
ផែនទីលេខ៤៖ ប្លង់ត្រពាំងនៃប្រាសាទខាងជើង........ ១៩
ផែនទីលេខ៥៖ ប្លង់ប្រាសាទបាតត្រពាំងប្រាសាទខាងជើង........ ២២

គំនូរប្លង់លេខ១៖ រូបពំនុះកាត់អ័ក្សជើងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង........ ៦
គំនូរប្លង់លេខ២៖ រូបពំនុះកាត់អ័ក្សជើងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង........ ៨
គំនូរប្លង់លេខ៣៖ រូបពំនុះកាត់អ័ក្សប្រាង្គកណ្តាលនៃប្រាសាទខាងត្បូង........ ១០
គំនូរប្លង់លេខ៤៖ រូបពំនុះកាត់អ័ក្សប្រាង្គខាងត្បូងនៃប្រាសាទខាងត្បូង........ ១២
គំនូរប្លង់លេខ៥៖ រូបពំនុះកាត់អ័ក្សប្រាង្គខាងជើងនៃប្រាសាទខាងត្បូង........ ១៣
គំនូរប្លង់លេខ៦៖ រូបពំនុះកាត់អ័ក្សប្រាសាទខាងជើង........ ២១

## សេចក្ដីផ្ដើម

បើយើងគិតក្នុងបរិបទគ្រួសារ ឪពុកម្ដាយរមែងខិតខំស្វែងរកទ្រព្យធនទុកឲ្យកូនចៅជំនាន់ក្រោយជាកេរមរតករបស់ខ្លួន។ ក្នុងនាមជាកូន ជាចៅក៏ខិតខំថែរក្សាដំណែលទាំងនោះឲ្យគង់វង្ស ទុកជាស្នាដៃបន្តទៅជំនាន់ក្រោយទៀត។ គ្រួសារតូចក៏មិនខុសអ្វីពីគ្រួសារធំដែរ អ្នកដឹកនាំប្រទេស ឬព្រះមហាក្សត្របានខិតខំកសាងស្នាដៃផ្សេងៗ មានដូចជាប្រាសាទបុរាណ ជាដើម ទុកជាមរតកក្នុងរាជរបស់ព្រះអង្គ។ ទំនៀមនេះក្លាយជាវប្បធម៌មួយដែលព្រះមហាក្សត្រខ្មែរបានបន្តធ្វើពីរាជមួយទៅរាជមួយទៀត។ ដូចនេះហើយទើបយើងឃើញកេរដំណែលទាំងនេះមាននៅពាសពេញផ្ទៃប្រទេស និងនៅក្នុងប្រទេសជិតខាងមួយចំនួនទៀត។ ប្រាសាទ ឬវិមានគឺជាមរតករបស់មនុស្សជាតិយូរអង្វែងដែលបង្ហាញពីអារ្យធម៌អតីតកាល និងការរីកចម្រើនរុងរឿងរបស់ចក្រភពខ្មែរ។ បើទោះបីជាប្រទេសឆ្លងកាត់សង្គ្រាមជាច្រើនក្នុងប្រវត្តិសាស្ត្រ កេរដំណែលទាំងនោះ នៅរក្សាទុកឱ្យក្មេងជំនាន់ក្រោយបានស្គាល់ កោតសរសើរ និងចាត់ទុកជាបេតិកភណ្ឌវប្បធម៌ជាតិ។

ការសិក្សាស្រាវជ្រាវ បានចាប់ផ្ដើមនៅដើមសតវត្សទី២០ ដោយមានអ្នកប្រាជ្ញជនជាតិបារាំងមួយចំនួនបានធ្វើការសិក្សាចុះបញ្ជីឈ្មោះប្រាសាទទូទាំងប្រទេសកម្ពុជា រួមមានលោក Lunet De Lajonquière លោក Etienne Aymonier និងលោក Bernard Phillipes Groslllier ជាដើម។ នាពេលថ្មីៗនេះ មន្ត្រីជំនាញបុរាណវត្ថុវិទ្យានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រួមសហការណ៍ជាមួយស្ថាប័នអន្តរជាតិមួយចំនួនកំពុងសិក្សា និងចុះបញ្ជីប្រាសាទ និងស្ថានីយបុរាណក្នុងបញ្ជីបេតិកភណ្ឌជាតិ។ ទោះជាយ៉ាងនេះហើយក្ដី នៅមានប្រាសាទមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជាពុំទាន់បានចុះបញ្ជីនៅឡើយទេ ដោយសារនៅពេលនោះ ប្រាសាទទាំងនោះស្ថិតក្នុងព្រៃជ្រៅ អ្នកស្រាវជ្រាវមិនអាចចូលដល់។ ក្រោយមកទៀត ប្រទេសកម្ពុជាត្រូវរអូសបន្លាយដោយសង្គ្រាមរាំរ៉ៃ ធ្វើឲ្យដំណើរការស្រាវជ្រាវ និងចុះបញ្ជីត្រូវអាក់ខាន ដូច្នេះហើយបានជាមានប្រាសាទមួយចំនួននៅមិនទាន់មានការសិក្សា និងចុះបញ្ជីនៅឡើយ តួយ៉ាងប្រាសាទដែលមានព្រៃក្រាស់ស្ថិតនៅតាមជួរភ្នំដងរែកជាដើម។

ក្នុងចំណោមនោះ ត្រពាំងប្រាសាទ គឺជាប្រាសាទមួយដែលមិនមានក្នុងសៀវភៅរបស់អ្នកប្រាជ្ញខាងលើ និងមិនទាន់មានការសិក្សានៅឡើយ។

ប្រាសាទត្រពាំងប្រាសាទ ស្ថិតក្នុងភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គឺស្ថិតនៅតាមបណ្ដោយជួរភ្នំដងរែក។ ស្រុកត្រពាំងប្រាសាទមានព្រំប្រទល់ខាងត្បូងជាប់ខេត្តសៀមរាប ខាងកើតជាប់ខេត្តព្រះវិហារ ខាងជើងជាប់ព្រំដែនប្រទេសសៀម និងខាងលិចជាប់ស្រុកអន្លង់វែងនៃខេត្តឧត្តរមានជ័យ ដែលមានផ្ទៃដីសរុប៣២៦៥២ហិចតា (National Committee for Sub-National Democratic Development (NCDD), 2009)។ ទឹកដីដែលគ្របដណ្ដប់ដោយព្រៃឈើក្រាស់មិនមានការតាំងទីរបស់ប្រជាជនច្រើនដូចនៅតំបន់ទំនាបកណ្ដាលនោះ មានវត្តមានប្រាសាទបុរាណ ដែលបច្ចុប្បន្នបានក្លាយជាទីតាំងផ្ដល់ឱកាសដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ពីវប្បធម៌ និងអារ្យធម៌នៅសម័យបុរាណ។

ប្រាសាទត្រពាំងប្រាសាទជាបណ្ដុំប្រាសាទពីរ ខណ្ឌដាច់ដោយផ្លូវលំមួយខ្សែផ្ដាប់ពីវត្តត្រពាំងប្រាសាទទៅទីប្រជុំជន។ តាមរយៈការសិក្សាសង្កេតរយៈពេលខ្លី ប្រាសាទទាំងពីរកសាងក្នុងរជ្ជកាលខុសគ្នា។ ទោះបីប្រាសាទទាំងពីរកសាងក្នុងពេលខុសគ្នា ប៉ុន្តែគឺក្នុងសម័យអង្គរដូចគ្នា។ យើងសន្មតហៅឈ្មោះប្រាសាទទាំងពីរ គឺប្រាសាទខាងជើងផ្លូវ និងប្រាសាទខាងត្បូងផ្លូវ។

- **គោលបំណងនិងអត្ថប្រយោជន៍នៃគម្រោង**

យើងមើលឃើញថា ប្រាសាទត្រពាំងប្រាសាទមិនទាន់ចុះបញ្ជី មិនទាន់សិក្សាស្រាវជ្រាវ និងមិនមានការចាប់អារម្មណ៍អភិរក្សពីស្ថាប័នណាមួយនៅឡើយ។

ការបែកបាក់នៃប្រាសាទត្រពាំងប្រាសាទកាន់តែមានទ្រង់ទ្រាយធំទៅៗ។ យើងសង្កេតឃើញការបាក់បែកប្រាសាទនេះដូចជាៈ

- ការបំផ្លាញដោយអាកាសធាតុ និងបរិស្ថានធម្មជាតិជុំវិញ។ រុក្ខជាតិធំៗដុះពីលើ និងក្បែរប្រាសាទបានបំផ្លាញតួ និងគ្រឹះប្រាសាទ។
- អាយុកាលប្រាសាទជាកត្តាមួយមិនអាចទប់ស្កាត់ចំពោះការបាក់បែករបស់ប្រាសាទ។
- ការជីកបំផ្លាញរុករកវត្ថុបុរាណសម្រាប់ជួញដូរ។
- ការបំផ្លាញពីមនុស្ស។

**គោលបំណងនៃការសិក្សាគម្រោងនេះមានៈ**

១-ស្វែងយល់ពីរចនាបទប្រាសាទត្រពាំងប្រាសាទ

២-ធ្វើផែនទីស្ថានីយ សម្រាប់ជំនួយដល់ការកំណត់បរិវេណប្រាសាទ ក៏ដូចជាការបង្ហាញទីតាំងស្ថានីយ និងបរិបទជុំវិញ។

៣-រៀបចំរមណីយដ្ឋានប្រាសាទត្រពាំងប្រាសាទ ដោយធ្វើការសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ រួមជាមួយអជ្ញាធរ ដែនដីចាប់ពីថ្នាក់ខេត្ត, ស្រុក, ឃុំ, និងភូមិ ដើម្បីកំណត់បរិវេណប្រាសាទ ជៀសវាងការរំខាន ឬបំផ្លាញប្រាសាទដោយប្រការណាមួយ។

៤-រៀបចំសំអាតបរិវេណប្រាសាទដោយសំអាតស្មៅដែលដុះជុំវិញតួប្រាសាទ ក៏ដូចជានៅក្នុងបរិវេណដែលបានកំណត់។

៥-ទៅថ្ងៃអនាគត យើងខ្ញុំនឹងរៀបចំអភិវឌ្ឍទេសចរណ៍ ដោយប្រែក្លាយរមណីយដ្ឋានត្រពាំងប្រាសាទជារមណីយដ្ឋានទេសចរណ៍វប្បធម៌សម្រាប់ប្រជាជនក្នុងតំបន់ ទេសចរជាតិ និងអន្តរជាតិ។ នេះជាគោលការណ៍យុទ្ធសាស្ត្រជាតិមួយរួមចំណែកការអភិវឌ្ឍន៍ នៅតំបន់ដាច់ស្រយាល និងនៅតាមព្រំដែន។ កិច្ចការទាំងនេះតម្រូវឱ្យយើងខ្ញុំរៀបចំជាផ្លាកសញ្ញាបង្ហាញពីវត្តមានប្រាសាទត្រពាំងប្រាសាទ។ ផ្លាកនេះនឹងដាក់តាំងនៅផ្លូវធំ និងផ្លូវមុខប្រាសាទ។ យើងធ្វើបដាបង្ហាញរូបភាពប្រាសាទត្រពាំងប្រាសាទ ដោយដាក់តាំងនៅផ្លូវធំ។

# ផែនទីបង្ហាញទីតាំងស្រុក ត្រពាំងប្រាសាទ ខេត្ត ឧត្តរមានជ័យ



# ជំពូកទី១៖ ប្រាសាទត្រពាំងប្រាសាទខាងត្បូង

ប្រាសាទត្រពាំងប្រាសាទមានពីរ ដែលមានចម្ងាយប្រមាណ៣០០ម៉ែត្រពីគ្នា។ នៅចន្លោះប្រាសាទទាំងពីរមានផ្លូវមួយភ្ជាប់ទៅកាន់ទីប្រជុំជនទីរួមស្រុក។ ទាក់ទងនឹងឈ្មោះប្រាសាទទាំងពីរ អ្នកស្រុកហៅឈ្មោះផ្សេងៗគ្នា។ ប្រាសាទនៅខាងត្បូងថ្នល់ មានឈ្មោះ **ប្រាសាទខាងត្បូង** ឬ **ប្រាសាទតូច**។ ចំណែកប្រាសាទខាងជើងថ្នល់មានឈ្មោះមួយថា **ប្រាសាទខាងជើង** ឬ **ប្រាសាទធំ**។



ប្រាសាទខាងត្បូង មានទីតាំងស្ថិតនៅខាងជើងទីប្រជុំជននៃទីរួមស្រុកត្រពាំងប្រាសាទ។ ការរៀបចំទីរួមស្រុក បន្ទាប់ពីសង្គ្រាមស៊ីវិលអូសបន្លាយអស់ជាច្រើនឆ្នាំ វត្តមួយបានរៀបចំកសាងឡើងនៅខាងលិចនៃប្រាសាទ។ នៅខាងជើងប្រាសាទខាងត្បូង ឬប្រាសាទខ្នាចារ (មានអ្នកស្រុកខ្លះហៅប្រាសាទខាងត្បូងថា "ប្រាសាទខ្នាចារ") មានប្រាសាទមួយទៀតដូចដែលបានរៀបរាប់ខាងលើ គឺ ប្រាសាទខាងជើង។ ប្រាសាទទាំងពីរសុទ្ធតែមានតដាកនៅចំពីមុខ គឺនៅចំទិសខាងកើតនៃប្រាសាទ។ តដាកស្ថិតនៅមុខប្រាសាទខាងត្បូង មានទំហំធំជាងតដាកនៅខាងកើតប្រាសាទខាងជើង។

ប្រាសាទខាងត្បូងជាប្រាសាទមានតួបី ដែលតួទាំងបីសង់លើខឿនតែមួយ ហោត្រៃ មានកស្សិណទឹកព័ទ្ធជុំវិញកំពែងថ្មបាយក្រៀម និងមានខ្លោងទ្វារនៅគ្រប់ទិសទាំងបួន ទិសខាងកើត លិច ជើង និងនៅខាងត្បូង។





គំនូរប្លង់លេខ១៖ រូបពំនុះកាត់អ័ក្សជើងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង

## ១-កស្សិណទឹក

កស្សិណទឹក ឬគូទឹកនៃប្រាសាទគឺជាសមាសភាពមួយនៃរចនាសម្ព័ន្ធប្រាសាទខ្មែរ។ គូទឹកជា និមិត្តរូបនៃសមុទ្រ ដែលក្នុងលិទ្ធិព្រហ្មញ្ញសាសនាទីស្ថានរបស់ព្រះឥសូរគឺភ្នំព្រះសុមេរុដែលព័ទ្ធជុំវិញដោយមហាសមុទ្រមួយ។ ប្រាសាទគឺជានិមិត្តរូបរបស់ទីស្ថាននៃព្រះឥសូរ ដូច្នេះប្រាសាទគឺជាភ្នំ រីឯគូទឹកគឺជាមហាសមុទ្រព័ទ្ធជុំវិញ។ ជាទូទៅ គូទឹករមែងសង់ព័ទ្ធជុំវិញប្រាសាទចាប់តាំងពីសម័យមុនអង្គរ រហូតដល់សម័យអង្គរ។ ករណីខ្លះដែលគេមិនអាចកសាងគូទឹកបាន ដោយសារប្រាសាទសង់លើភ្នំ គេក៏អាចសង់ត្រពាំងមួយនៅក្បែរនោះ ឬនៅក្បែរភ្នំនោះ មានប្រព័ន្ធទឹកធម្មជាតិ គេមិនចាំបាច់កសាងត្រពាំងឡើយ។ នៅតំបន់ភាគខាងត្បូងប្រទេសកម្ពុជា យើងសង្កេតឃើញមានទួលប្រាសាទបាក់បែក ឬទួលប្រាសាទច្រើនសង់នៅសម័យមុនអង្គរ សុទ្ធតែមានគូទឹកព័ទ្ធជុំវិញ (មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ២០០៦)។



រូបលេខ១៖ កស្សិណទឹកប្រាសាទខាងត្បូង ជ្រុងឦសាន

អ្នកស្រាវជ្រាវបរទេសខ្លះឱ្យឈ្មោះទួលប្រាសាទទាំងនោះ ជាភាសាអង់គ្លេសថា *Moated Mound* មានន័យថា “ទួលប្រាសាទមានគូទឹកព័ទ្ធជុំវិញ”។

ប្រាសាទខាងត្បូងមានគូទឹកព័ទ្ធស្ទើតែជុំវិញ ទុកតែច្រកចូលប្រាសាទនៅទិសខាងកើត។ គូទឹកនេះមានជម្រៅជ្រៅនិងរាក់ទៅតាមកន្លែង។ នៅជ្រុងខាងជើងឈៀងខាងកើតនៅមានទឹកដក់។ នៅពេលបច្ចុប្បន្ន គោក្របីអ្នកភូមិមកផឹកទឹក និងដេកត្រាំទឹកនៅក្នុងគូទឹកនេះ។

គូទឹកនេះមានទទឹងពីជើងទៅត្បូងប្រវែង១០៥ម៉ែត្រ និងបណ្តោយពីកើតទៅលិចប្រវែង១០៨ម៉ែត្រ។

## ២-កំពែងនិងខ្លោងទ្វារ

កំពែងជាសមាសធាតុមួយនៃប្រាសាទ។ រហូតដល់សម័យអង្គរ ទើបមានលេចចេញថែវប្រាសាទ។ កំពែងប្រាសាទខាងត្បូងសង់ពីថ្មបាយក្រៀម។ កំពែងនេះមានទទឹងពីជើងទៅត្បូងប្រវែង៣៧ម៉ែត្រ និងបណ្ដោយពីកើតទៅលិចប្រវែង៤០ម៉ែត្រ។

នៅគ្រប់ជ្រុងនៃកំពែង មានខ្លោងងទ្វារចូលប្រាសាទ។ ប្រាសាទខាងត្បូងមានខ្លោងទ្វារចូលបួននៅគ្រប់ទិស។ ខ្លោងទ្វារប្រាសាទធ្វើពីឥដ្ឋ និងស៊ុំទ្វារធ្វើពីថ្មភក់។ ខ្លោងទ្វារខាងលិចនិងខាងកើត សង់ចំពាក់កណ្ដាលកំពែង ចំណែកខ្លោងទ្វារខាងជើងនិងត្បូងសង់មិនចំពាក់កណ្ដាលនៃកំពែងទេ។



រូបលេខ២៖ កំពែងប្រាសាទខាងត្បូង ជ្រុងឦសាន

## ៣-ខឿនប្រាសាទ

ប្រាសាទខាងត្បូងមានតួប្រាសាទបី។ តួប្រាសាទទាំងបីសង់លើខឿនរួមមួយដែលមានប្រវែងប្រហាក់ប្រហែល គឺពីជើងទៅត្បូងប្រវែង២៦ម៉ែត្រ និងពីកើតទៅលិចប្រវែង២០ម៉ែត្រ។ ខឿនប្រាសាទសង់ពីថ្មបាយក្រៀមព័ទ្ធជុំវិញ។ ខឿនប្រាសាទនេះ លយចេញនៅចំពីមុខតួប្រាសាទកណ្ដាល។ នៅកន្លែងលយនេះមានជណ្ដើរឡើងឆ្ពោះទៅកាន់តួកណ្ដាលនិងតួប្រាសាទពីរទៀត។ ដោយសារការបាក់បែកខ្លាំង នៅខឿននេះយើងពិបាកសន្និដ្ឋានថា តើមានជណ្ដើរនៅចំពីមុខតួប្រាសាទពីរទៀត ឬក៏គ្មាន។ យើងអាចដឹងបាន ដរាបណា យើងធ្វើកំណាយនៅខាងកើតនៃខឿននេះ។



រូបលេខ៣៖ ទិដ្ឋភាពខឿនប្រាសាទខាងត្បូង នៅទិសខាងកើត




គំនូរប្លង់លេខ២៖ រូបពំនុះកាត់អ័ក្សជើងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង

## ៤-ប្រាង្គនៃប្រាសាទ

### ៤-ក. ប្រាង្គកណ្ដាល

ប្រាង្គកណ្ដាលជាប្រាង្គសំខាន់ជាងគេបំផុត ហើយជាទូទៅមានទំហំធំជាង និងខ្ពស់ជាងប្រាង្គដ៏ទៃទៀត។ ប្រាង្គកណ្ដាលនៃប្រាសាទខាងត្បូងមានកំពស់ ៦.៣ម៉ែត្រ និងកម្រាស់ជញ្ជាំង ១.៣ ម៉ែត្រ ប្រាង្គនេះទទួលរងការបំផ្លាញច្រើន។ ដំបូលប្រាសាទដែលជាទូទៅធ្វើពីថ្មភក់ មានរាងដូចផ្កាឈូកក្រពុំបានជ្រុះបាត់ រីឯសំណល់ដំបូលប្រាសាទនេះ ប្រហែលជាក្នុងបរិវេណវត្តបច្ចុប្បន្ន។ ប្រាង្គនេះសង់ពីឥដ្ឋសម្រាប់តួប្រាសាទទាំងមូល លើកលែងគ្រឿងលម្អ ដូចជា ផ្តែរ មេទ្វារ សសរផ្អោប កាំជណ្ដើរ និងទ្រនាប់ជណ្ដើធ្វើពីថ្មភក់។ ការប្រើថ្មភក់សម្រាប់គ្រឿងលម្អប្រាសាទបែបនេះ ជាលក្ខណៈទូទៅសម្រាប់សំណង់ប្រាសាទក្នុងប្រទេសកម្ពុជា

និងប្រាសាទផ្សេងៗក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ មានការប្រើថ្មភក់នៅទ្វារបញ្ឆោតនៅជ្រុងខាងលិច។ គួរកត់សម្គាល់ថា នៅគ្រប់ប្រាង្គទាំងបីនៃប្រាសាទខាងត្បូងមិនមានយកថ្មភក់មានសង់នៅត្រង់ទ្វារបញ្ឆោតនោះទេ លើកលែងតែទ្វារបញ្ឆោតនៅតួកណ្ដាល ហើយមានតែនៅជ្រុងខាងកើតមួយគត់ដែលប្រើថ្មភក់នៅលើទ្វារបញ្ឆោត។ ទ្វារបញ្ឆោតនៅជ្រុងខាងជើង និងខាងត្បូងប្រាសាទត្រូវឆ្លាក់ និងដាប់នៅលើឥដ្ឋនៃជញ្ជាំងប្រាសាទឲ្យចេញជារាងទ្វារបញ្ឆោត។ យើងសង្កេតឃើញថា នៅរចនាសម្ព័ន្ធផ្នែកខាងក្រោមនៅជាប់ដី គេក៏ប្រើថ្មភក់ដែរ ហើយមានលម្អដោយឆ្លាក់ក្បាច់នៅលើថ្មទាំងនោះ។ ការយកថ្មភក់មកប្រើនៅរចនាសម្ព័ន្ធក្រោមនៃប្រាសាទជាការមួយងាយស្រួលឆ្លាក់លម្អក្បាច់ ជាងនេះទៀត ថ្មភក់អាចជួយទ្រនិងទប់កម្លាំងសង្កត់របស់តួប្រាសាទ ជួយពង្រឹងរចនាសម្ព័ន្ធប្រាសាទឲ្យរឹងមាំល្អ។ ក្រៅពីគ្រឹះនៅខាងក្រោមប្រាសាទ និងខឿនដែលជួយទប់ដល់ការបាក់ស្រុត បច្ចេកទេសយកថ្មភក់មកប្រើនៅរចនាសម្ព័ន្ធក្រោមអាចជួយកម្លាំងទ្របន្ថែមទៀត។



រូបលេខ២៤៖ ប្រាង្គកណ្ដាលនៃប្រាសាទខាងត្បូង

ទាក់ទងការបំផ្លាញចំពោះប្រាសាទ ប្រាង្គកណ្ដាលនៃប្រាសាទខាងជើងទទួលរងការបំផ្លាញមិនខុសពីប្រាសាទនានាក្នុងប្រទេសកម្ពុជា ជាពិសេសប្រាសាទឥដ្ឋ។ ជាធម្មតា ប្រាសាទឥដ្ឋកសាងឡើងដោយមានកំពស់ខ្ពស់ទៅលើ ហើយមានកម្រាស់ក្រាស់។ ឧទាហរណ៍ តួប្រាសាទនៅក្រុមប្រាសាទសម្បូរណ៍ព្រៃគុកមានកំពស់រហូតដល់១៨ម៉ែត្រ និងមានកម្រាស់២ម៉ែត្រ។ បច្ចេកទេសសំណង់បែបនេះ បង្កើនឱ្យមានកម្លាំងសង្កត់ខ្លាំង។ ស្ថាបត្យករបានគិតដល់បញ្ហានេះ ហើយបានសង់គ្រឹះយ៉ាងរឹងមាំ អមជាមួយនឹងខឿនជួយទប់សំណឹកសងខាងនៃតួប្រាសាទថែមទៀត។ ប៉ុន្តែមានចំណុចមួយដែលយើងសង្កេតឃើញថា ប្រាសាទនៅស្ថានីយជា

ច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជាទទួលរងការបំផ្លាញខ្លាំងនៅជ្រុងខាងកើត គឺនៅចំពីលើផ្តែរទ្វារ។ ធម្មតាទ្វារសង់ដើម្បីឱ្យយើងអាចចេញ ចូលបាន។ ដើម្បីទ្រកម្លាំងសង្កត់នៃតួប្រាសាទទាំងមូល គេយកធ្នឹមមួយទៀតទ្រពីលើមេទ្វារ។ ទោះយ៉ាងណា ក្រោយពីសំណង់មានអាយុកាលរាប់រយឆ្នាំ កម្លាំងសង្កត់នៃតួប្រាសាទធ្វើឱ្យធ្នឹម និងមេទ្វារបែក និងធ្លាក់ចុះមកក្រោម។ បន្ទាប់ពីមេទ្វារបាក់ ផ្តែរក៏ទទួលរងការខូចខាត និងធ្លាក់របេះចុះមកដី។ ចំណែកឯឥដ្ឋដែលនៅជ្រុងខាងកើតនេះក៏ចាប់ផ្តើមធ្លាក់ជ្រុះមកដីជាបន្តបន្ទាប់ ធ្វើឱ្យជ្រុងខាងកើតហាក់ដូចជាទទួលរងការខូចខាតខ្លាំងជាងជ្រុងផ្សេងៗទៀត។

ករណីនេះក៏កើតមាននៅប្រាង្គទាំងអស់នៅប្រាសាទត្រពាំងប្រាសាទខាងត្បូងដែរ។ ប្រាង្គកណ្តាលនៅជ្រុងខាងកើតទទួលរងខូចខាតខ្លាំង។ ធ្នឹមទ្វារ មេទ្វារបានធ្លាក់ជ្រុះបាត់ពីតួប្រាសាទ។ ផ្តែរក៏ជ្រុះរបេះបាត់ហើយប្រហែលជាផ្តែរនៅដីដែលបែកជាពីរបំណែក និងមានតែមួយចំហៀងនេះ ជាផ្តែរនៃប្រាង្គកណ្តាល។ ឥដ្ឋនៅជញ្ជាំងខាងកើតជាច្រើនបានជ្រុះមកក្រោម ធ្វើឱ្យជញ្ជាំងខាងកើត ទទួលរងខូចខាតខ្លាំងជាងគេ។




គំនូរប្លង់លេខ៣៖ រូបពំនុះកាត់អ័ក្សប្រាង្គកណ្តាលនៃប្រាសាទខាងត្បូង

## ៤-ខ. ប្រាង្គខាងត្បូង

ក្រៅពីប្រាង្គកណ្តាលជាប្រាង្គសំខាន់ នៅមានប្រាង្គពីរទៀតនៅអមសងខាងប្រាង្គកណ្តាល។ ប្រាង្គខាងត្បូងមានកំពស់២.៥ម៉ែត្រ និងមានកម្រាស់ជញ្ជាំង ១.៣ ម៉ែត្រ។ ប្រាង្គនេះក៏ទទួលរងការបំផ្លាញខ្លាំងដែរ គឺមានសភាពទ្រុឌទ្រោមខ្លាំងជាងប្រាង្គកណ្តាល។ រចនាសម្ព័ន្ធខាងលើ គឺដំបូលប្រាសាទបានជ្រុះបាត់។ ប្រាង្គនេះសង់ពីឥដ្ឋ លើកលែងគ្រឿងលម្អ ដូចជា ផ្តែរ មេទ្វារ សសរផ្តោប ជណ្តើរ និងទ្រនាប់

ជណ្ដើរធ្វើពីថ្មភក់។ ចំពោះប្រាង្គខាងត្បូងវិញ គ្រឿងលម្អធ្វើពីថ្មភក់មាននៅសេសសល់តែសសរផ្ដោបមួយ និងបំណែកសសរពេជ្រមួយប៉ុណ្ណោះ។ សម្រាប់ទ្វារបញ្ឆោតវិញ គេប្រើបច្ចេកទេសដូចគ្នានឹងទ្វារបញ្ឆោតនៃប្រាង្គកណ្ដាលដែរ តែមិនមានប្រើថ្មភក់ជាមួយទេ។

បើនិយាយពីការខូចខាតវិញប្រាង្គនេះទទួលរងការបំផ្លាញខ្លាំង។ ផ្តែរ ស៊ុំទ្វារ សសរពេជ្របានជ្រុះបាត់ពីប្រាសាទ រីឯជញ្ជាំងខាងកើតបាត់ទាំងស្រុង។ នៅគ្រប់ជញ្ជាំងផ្នែកខាងលើបាក់បែកទាំងស្រុង។ ប្រាង្គនេះរកកល់នឹងរលំទៅខាងទិសខាងត្បូង។ យើងឃើញថា ប្រាង្គនេះទ្រេតខ្លាំងទៅទិសខាងត្បូង។ ជញ្ជាំងខាងត្បូងបានរហែក ញែកដាច់ចេញពីជញ្ជាំងខាងលិចទាំងស្រុង។

បន្ទាប់ពីធ្វើការសិក្សាវិភាគ និងគូរផែនទីប្លង់ប្រាសាទរួចមក យើងអាចស្វែងយល់ពីមូលហេតុដែលបណ្ដាលឲ្យជញ្ជាំងខាងត្បូងប្រេះទ្រេតទៅខាងត្បូង។ បញ្ហានេះកើតដោយសារការស្ថាបនាខឿនប្រាសាទមិនបានធំល្មសម្រាប់ទ្រប្រាង្គទាំងបី។ ខឿនប្រាសាទសង់ខ្ពស់ ប៉ុន្តែតូច ហើយមានកសាងប្រាង្គបីនៅពីលើបន្ថែមទៀត។ ពីប្រាង្គទៅចុងខឿនមានចម្ងាយខ្លី ដូច្នេះនៅពេលខឿនបាក់ កម្លាំងទប់ប្រាង្គក៏ចុះខ្សោយ។ នៅពេលមានភ្លៀងធ្លាក់ ទឹកភ្លៀងនាំហូរដីចេញពីខឿន បានធ្វើឲ្យគ្រឹះនៃប្រាង្គលែងមានអ្វីទប់ ហើយក៏ទ្រេត ទៅតាមតាមទិសដែលខឿនបាក់បែក។ ករណីនេះ កើតឡើងចំពោះប្រាង្គខាងត្បូង និងប្រាង្គខាងជើង ដោយសារខឿននៅជ្រុងខាងត្បូង និងខាងជើងស្ថាបនានៅជិតប្រាង្គទាំងពីរ ដល់ពេលខឿនបាក់បែក ប្រាង្គទាំងពីរក៏លែងមានខឿនទប់ទៀតហើយក៏បាក់បែកបន្ទាប់ពីខឿននោះដែរ។



រូបលេខ៥៖ ប្រាង្គខាងត្បូងនៃប្រាសាទខាងត្បូង




គំនូរប្លង់លេខ៤៖ រូបពំនុះកាត់អ័ក្សប្រាង្គខាងត្បូងនៃប្រាសាទខាងត្បូង

### ៤-គ. ប្រាង្គខាងជើង

ប្រាង្គទីបីគឺប្រាង្គខាងជើងនៃជញ្ជាំងខាងជើងមានកំពស់ ៦ ម៉ែត្រ ចំណែកជញ្ជាំងខាងត្បូងមានកំពស់ ៤.៨ ម៉ែត្រ និងកម្រាស់ជញ្ជាំង ១.៣ ម៉ែត្រ ប្រាង្គនេះទទួលរងការបំផ្លាញខ្លាំងជាងគេក្នុងចំណោមប្រាង្គទាំងបីនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង។ រចនាសម្ព័ន្ធខាងលើ គឺជំបូលប្រាសាទបានជ្រុះបាត់ស្ទើតែទាំងអស់ តួប្រាសាទទាំងមូលនៅសេសសល់តិចតួចបំផុត។ ប្រាង្គនេះក៏ដូចជាប្រាង្គដ៏ទៀតដែរ គឺសង់ពីឥដ្ឋ លើកលែងគ្រឿងលម្អ ដូចជា ផ្តែរ មេទ្វារ សសរផ្តោប កាំជណ្តើរ និងទ្រនាប់ជណ្តើធ្វើពីថ្មភក់។ ប្រាង្គខាងជើង គ្រឿងលម្អធ្វើពីថ្មភក់មាននៅសេសសល់តែមេទ្វារមួយប៉ុណ្ណោះ ចំណែកគ្រឿងលម្អផ្សេងៗមិនមានសេសសល់ឡើយ។

បើនិយាយពីការខូចខាតវិញប្រាង្គខាងជើងនេះទទួលរងការបំផ្លាញខ្លាំងបំផុត។ ផ្តែរស៊ុំទ្វារ សសរពេជ្របានជ្រុះបាត់ពីប្រាសាទ រីឯជញ្ជាំងខាងកើតបាត់ទាំងស្រុងដូចប្រាង្គខាងត្បូងដែរ។ នៅគ្រប់ជញ្ជាំងផ្នែកខាងលើបាក់បែកទាំងស្រុង។ ប្រាង្គខាងជើងមានលក្ខណៈបំផ្លាញដូចគ្នានឹងប្រាង្គខាងត្បូងដែរ។ ដូចបានលើកឡើងពីខាងលើរួចមកហើយ បញ្ហាចម្បងបណ្តាលឲ្យប្រាង្គទ្រុឌទ្រោមខ្លាំងគឺដោយសារខឿននៃប្រាសាទបានបាក់បែក។ ដោយហេតុថា ប្រាង្គនេះសង់ក្បែរខឿន ហើយខឿនទៀតសោតតូច តែខ្ពស់។ ដូច្នេះនៅពេលខឿនទទួលរងការបាក់បែក ប្រាង្គដែលសង់ពីលើខឿនក៏ទទួលរងការបំផ្លាញស្របគ្នាដែរ។ ប្រាង្គខាងជើងទ្រេតទៅទិសខាងជើង គឺទ្រេតទៅរកខឿនដែលទទួលរងការបាក់បែក។ ចំណែកជញ្ជាំងខាងជើងទ្រេតខ្លាំងជាងគេ និងទទួលរងការបំផ្លាញខ្លាំងជាងគេដែរ។



រូបលេខ២៦៖  ប្រាង្គខាងជើងនៃប្រាសាទខាងត្បូង




គំនូរប្លង់លេខ២៥៖ រូបពំនុះកាត់អ័ក្សប្រាង្គខាងជើងនៃប្រាសាទខាងត្បូង

## ៥-ហោជាង

ប្រាសាទខាងត្បូងត្រូវបាក់ទ្រុឌទ្រោមយ៉ាងខ្លាំង។ គ្រឿងលម្អប្រាសាទដូចជាហោជាង ផ្តែរ និងសសរស្តម្ភជាដើម ត្រូវធ្លាក់ចុះពីប្រាសាទនិងបាក់បែកជាបំណែក។ យើងសង្កេតឃើញមានបំណែកហោជាងពីរបំណែកស្ថិតក្នុងបរិវេណប្រាសាទ។ តាមរយៈបំណែកហោជាងទាំងពីរ ហោជាងនោះប្រហែលមានទំហំធំ ហើយបំណែកទាំងពីរជាបំណែកខ្លះនៃហោជាង។ យើងឃើញមានរចនាលម្អជាបែបរចនាបថសម័យអង្គរ និងមានលម្អសត្វស្លាបមួយ ប្រហែលជាសត្វសេក។





រូបលេខ៧ និង៨៖ បំណែកហោជាងប្រាសាទខាងត្បូង

## ៦-សសរស្តម្ភ

សសរស្តម្ភ ឬសសរពេជ្រ គឺជាគ្រឿងលម្អស្ថាបត្យកម្មមួយ ប្រើសម្រាប់ទ្រផ្តែរ។ ជាទូទៅសសរស្តម្ភរបស់ប្រាសាទបុរាណខ្មែរធ្វើពីថ្មភក់។ លោកហ្វីលីព ស្តែន Phillipe Stern និងអ្នកស្រីស្សីលប៉ៃ ដឺ កូរាល រេមុយស្សា (Gilbert de Coral Rémusat) បានចែកសសរស្តម្ភសម័យមុនអង្គរជាបី៖ សសរស្តម្ភក្នុងរចនាបថសម្បូណ៌ព្រៃគុក នៅកំលុងសតវត្សទី៧ សសរស្តម្ភសម័យព្រៃក្មេងនៅកំលុងភាគទី១នៃសតវត្សទី៨ និងសសរស្តម្ភក្នុងរចនាបថកំពង់ព្រះ នៅកំលុងពាក់កណ្តាលសតវត្សទី៨។ សសរស្តម្ភក្នុងរចនាបទទាំងបីខាងលើជាទូទៅរាងមូលហើយតូច។ សសរស្តម្ភក្នុងរចនាបថក្រោយៗកាន់តែធំ និងមានក្បាច់លម្អកាន់តែស្មុគស្មាញ។ ម្យ៉ាងទៀតក្បាច់រចនារបស់សសរស្តម្ភតែងតែវិវត្តស្របគ្នាជាមួយនឹងក្បាច់លម្អរបស់ផ្តែរ(Brigg,

1951)។ អ្នកស្រីស្សឺលប៊ែ ដឺ កូរាល រេមុយស្សា (Gilbert de Coral Rémusat) បានធ្វើការកត់សម្គាល់ពីការវិវត្តន៍ ដោយសង្ខេបតាមដំណាក់កាលនីមួយៗនៃសិល្បៈរូបចមកហើយ (Rémusat, 1951)។

ជាទូទៅសសរស្តម្ភធ្វើឡើងអំពីថ្មភក់តែមួយដុំ ហើយមានតួនាទីសម្រាប់ទ្រផ្តែរទ្វារផង និងបង្កើនសោភ័ណភាពប្រាសាទផង។ នៅសម័យមុនអង្គរសសរស្តម្ភមានរាងមូលដូចជាបំពង់។ ជាក់ស្តែងដូចជានៅក្រុមប្រាសាទសម្បូណ៌ព្រៃគុកលើកលែងតែប្រាសាទតោ ដែលជាប្រាសាទស្ថិតនៅក្នុងរចនាបថអន្តរកាលពីសម័យមុនអង្គរមកដើមសម័យអង្គរ។ នៅសម័យអង្គរសសរស្តម្ភមានរាងប្រាំបីជ្រុងដូចជា ប្រាសាទវត្តឯកភ្នំ ប្រាសាទក្រវ៉ាន់ ជាដើម។



រូបលេខ៩៖ សសរស្តម្ភប្រាសាទខាងត្បូង



រូបលេខ១០៖ សសរស្តម្ភប្រាសាទខាងត្បូង

### ៧-សសរផ្កោប

សសរផ្កោបក៏ដូចជាសសរស្តម្ភ និងគ្រឿងលម្អផ្សេងទៀតដែរ គេស្ថាបនាឡើងនៅបន្ទាប់ពីសសរស្តម្ភ និងមានរចនាក្បាច់លម្អដូចជាក្បាច់ភ្ញីផ្សេងៗជាដើម។ សសរផ្កោបមានបីប្រភេទខុសៗគ្នាគឺ សសរផ្កោបសំខាន់ (មេ) សសរផ្កោបសារពើសូត្រ និងសសរផ្កោបជ្រុងដែលមានតាំងពីសម័យមុនអង្គររហូតមកដល់សម័យក្រោយៗទៀត រហូតដល់សម័យអង្គរ។ សសរផ្កោបអាចសាងពីថ្មភក់ដាច់ដោយឡែកពីសសរស្តម្ភ។ ទំនោរបែបនេះច្រើនកើតមាននៅទ្វារចូលនៃប្រាង្គប្រាសាទដែលយើងអាចមើលឃើញមេទ្វារ ឬស៊ុំទ្វារ ផ្តែរ ហោជាង សសរស្តម្ភ និងបន្តដោយសសរផ្កោប។ សសរផ្កោបខ្លះទៀតអាចកសាងនៅជាប់ជាមួយទ្វារបញ្ឆោតនៃប្រាង្គ។ ចំពោះប្រាសាទត្រពាំងប្រាសាទវិញ គេជ្រើសរើសករណីទាំងពីរមកប្រើ។ នេះមានន័យថា បច្ចេកទេសស្ថាបនាប្រាសាទមានការរីកចំរើន។ តែដោយឡែក សសរផ្កោបនៅតួប៉មនៃប្រាសាទស្លាប់ប្តីវិញសាងនៅជាប់ទ្វារបញ្ឆោត ហើយពុំមានឆ្លាក់ក្បាច់អ្វីទេនៅឯតួសសរ តែនៅក្បាលសសរមានចិតជាក្បាច់ខ្សែវន្ទ័បីជាន់តែប៉ុណ្ណោះ (កើត គឹមហៃ ២០០៦)។



រូបលេខ១១៖ សសរផ្កោបនៃប្រាង្គខាងជើង របស់ប្រាសាទខាងត្បូង សាងពីថ្មភក់ នៅបន្តពីសសរស្តម្ភ

### ៨-ផ្តែរ

ផ្តែរជាគ្រឿងលម្អមួយផ្នែកសំណង់ស្ថាបត្យកម្ម ដាក់ពីលើសសរស្តម្ភ លើខ្លោងទ្វារចូលប្រាសាទ។ សិល្បៈសំណង់ប្រាសាទបុរាណខ្មែរតាំងពីសម័យហ្វូណនមកម្ល៉េះ ហើយស្នាដៃសិល្បៈនេះចេះតែវិវត្តហូរហែមករហូតដល់សម័យបាយ័ន។ ដើម្បីសម្រួលដល់ការសិក្សា គេនិយមចែកសិល្បៈជារចនាបថ ដោយយកឈ្មោះប្រាសាទសំខាន់ៗមកដាក់ឈ្មោះរចនាបថទាំងនោះ។ ផ្តែរក្នុងសិល្បៈខ្មែរក៏ចែកទៅតាមសម័យកាល និងរចនាបថដែរ។ តាមទ្រឹស្តីសិល្បៈ គេអាចចែកសម័យកាលប្រវត្តិសាស្ត្រដោយសារការវិវត្តន៍ក្បាច់លម្អរបស់គ្រឿងសំណង់ស្ថាបត្យកម្ម។ ផ្តែរជាផ្នែកមួយសំខាន់សម្រាប់សិក្សារចនាបថប្រាសាទនីមួយៗ ហើយលោក ហ្វីលីពស្តែន (P. Stern) បានសិក្សាពីការវិវត្តន៍របស់វា។

មានសំណល់បំណែកផ្តែរមួយផ្ទាំងស្ថិតក្នុងបរិវេណខាងក្នុងប្រាសាទត្រពាំងប្រាសាទខាងត្បូង។ ផ្តែរបាក់ជាបួនបំណែក។ បំណែកពីរនៅខាងលើបាត់ គឺនៅសល់តែបំណែកពីរខាងក្រោម។ ការបាក់បែកនេះអាចបណ្តាលមកពីការបាក់រលំនៃសសរស្តម្ភ ធ្វើឲ្យផ្តែរនៅខាងលើធ្លាក់មកក្រោមបាក់ជាបំណែក។ ករណីបាក់បែកមួយទៀតអាចទាក់ទងនឹងការលួចវត្ថុបុរាណរបស់ពួកក្រុមចោរ។ អំពើរចោរកម្មលើប្រាសាទ

បុរាណ រូបបដិមា គ្រឿងលម្អប្រាសាទបុរាណកើតមាននៅពេញផ្ទៃប្រទេសក្នុងពេលស្រុកកំពុងមានសង្គ្រាមផ្ទៃក្នុង។ ម្លោះហើយ ផ្តែរនេះអាចមានករណី វាយបំបែកជាបំណែកមុននឹងលួចយកចេញទៅ។

ចម្លាក់នៅលើផ្តែរៈ មានរូបព្រះកាលស្ថិតនៅចំកណ្តាល ប៉ុន្តែធ្លាក់ចុះក្រោម។ ព្រះកាលមានដៃកាន់កម្រងផ្កាដាក់នៅក្បែរមាត់។ ក្បាលព្រះកាលមានសក់រួញដូចសត្វសឹង្ហ។ ភ្នែកព្រះកាល ធំៗ និងលៀនចេញមកក្រៅ។ ច្រមុះធំរីក មានរន្ធធំៗ។ ធ្មេញបង្ហាញយ៉ាងច្បាស់លាស់ ទាំងធ្មេញលើ និងធ្មេញក្រោម។ កាយវិការមាត់បើកធំបញ្ចេញធ្មេញ និងចង្កូម ព្រមជាមួយដៃកាន់កម្រងផ្កាបែបនេះ អាចជាកាយវិការលេប ឬខ្ជាក់កម្រងផ្កា។ នៅសងខាងរូបព្រះកាល គឺជាកម្រងផ្ការដែលព្រះកាលកំពុងលេប ឬខ្ជាក់នោះ។ ផ្កាជាប្រភេទផ្កាមានសន្លឹកធំៗ ហើយរីកទល់ខ្នងគ្នា។ ចំណែកនៅខាងចុងផ្តែរទាំងសងខាង គឺជាសន្លឹកផ្ការីកបែរចេញក្រៅ។



រូបលេខ១២៖ បំណែកផ្តែរពីរផ្ទាំងផ្គុំគ្នា ស្ថិតក្នុងបរិវេណប្រាសាទខាងត្បូង

## ៩-លិង្គ

លិង្គគឺជាតំណាងអង្គជាតិរបស់ព្រះឥសូរ និងជាតំណាងឲ្យអំណាចនៃការបង្កើតលោក។ លិង្គគឺជានិមិត្តរូបសាសនាមួយដែលមានតួនាទីចម្បងសម្រាប់គោរពសក្ការៈ។ នៅក្នុងរាជព្រះមហាក្សត្រខ្មែរ លិង្គកសាងឡើងជានិមិត្តរូបរបស់ព្រះមហាក្សត្រផ្ទាល់ និងតម្កល់នៅក្នុងប្រាង្គប្រាសាទរបស់ព្រះអង្គដែលបានកសាង សន្មតថាព្រះអង្គគឺជាព្រះឥសូរ។ ការកសាងលិង្គចាប់ ផ្តើមមានតាំងពីសម័យមុនអង្គរហូតដល់សម័យអង្គរ។ លិង្គនៅសម័យអង្គរមានច្រើនប្រភេទ៖ លិង្គខ្លះដាក់តម្កល់លើយោនី, លិង្គខ្លះមានឆ្លាក់មុខរបស់ព្រះឥសូរដែល គេច្រើនហៅថា មុខលិង្គ(mukhalinga) និងលិង្គខ្លះទៀតសាងជាបីផ្នែកគឺ នៅបាតរាងបួនជ្រុងតំណាងឲ្យព្រះព្រហ្ម, នៅផ្នែកកណ្តាលរាងប្រាំមួយជ្រុង តំណាងឲ្យព្រះនារាយណ៍ និងផ្នែកខាងលើបំផុតរាងមូល តំណាងឲ្យ ព្រះឥសូរ។



រូបលេខ១៣៖ លិង្គនៅក្នុងបរិវេណប្រាសាទខាងត្បូង

នៅប្រាសាទត្រពាំងប្រាសាទ មានសល់បំណែកលិង្គតែមួយគត់នៅក្នុងបរិវេណប្រាសាទ។ លិង្គនេះ ជាប្រភេទលិង្គទីបីដែលមានបីផ្នែកគឺ នៅបាតរាងបួនជ្រុងតំណាងឲ្យព្រះព្រហ្ម, នៅផ្នែកកណ្ដាលរាងប្រាំមួយជ្រុងតំណាងឲ្យព្រះនារាយណ៍ និងផ្នែកខាងលើបំផុតរាងមូល តំណាងឲ្យព្រះឥសូរ។ ក៏ប៉ុន្តែផ្នែកខាងលើបានបែកនៅសល់ផ្នែកខាងក្រោម និងកណ្ដាល។



រូបលេខ១៤៖ ទិដ្ឋភាពប្រាសាទត្រពាំងប្រាសាទខាងត្បូង មើលពីទិសនិរតី

# ជំពូកទី២៖ ប្រាសាទត្រពាំងប្រាសាទខាងជើង

ប្រាសាទខាងជើង ឬប្រាសាទធំ ស្ថិតនៅខាងជើងទីប្រជុំជនស្រុកត្រពាំងប្រាសាទ ហើយក៏ស្ថិតនៅខាងជើងនៃប្រាសាទខាងត្បូងដែរ។

ប្រាសាទខាងជើងជាប្រាសាទមានប្រាង្គទោល មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ហោត្រៃស្ថិតនៅទិសឦសាន និងមានខ្លោងទ្វារតែមួយគត់ ស្ថិតនៅទិសខាងកើត។ ប្រាសាទខាងជើងពុំមានកសិណទឹកព័ទ្ធជុំវិញដូចប្រាសាទខាងត្បូងទេ តែមានតដាកមួយស្ថិតនៅខាងកើតនៃប្រាសាទ។ តដាកនេះមានបណ្ដោយប្រវែង២០០ម៉ែត្រ និងទទឹង៥១ម៉ែត្រ និងផ្ទៃក្រឡាជាង២០០០០ម៉ែត្រក្រឡា។




## ១-កំពែងនិងខ្លោងទ្វារ

ប្រាសាទខាងជើងក៏មានកំពែងដូចប្រាសាទខាងត្បូងដែរ។ កំពែងប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម។ កំពែងនេះមានទទឹងពីជើងទៅត្បូងប្រវែង២៣ម៉ែត្រ និងបណ្ដោយពីកើតទៅលិចប្រវែង ៣៥ ម៉ែត្រ។ ប្រាសាទខាងជើងពុំមានខ្លោងទ្វារចូលបួននៅគ្រប់ទិស គឺមានតែខ្លោងទ្វារតែមួយគត់នៅជ្រុងខាងកើត។ ខ្លោងទ្វារខាងកើតធ្វើពីថ្មបាយក្រៀមនិងស៊ុំទ្វារធ្វើពីថ្មភក់។



រូបលេខ១៥៖ ខ្លោងទ្វារខាងកើតនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម

## ២-ប្រាង្គប្រាសាទ

ប្រាសាទខាងជើងមានប្រាង្គតែមួយគត់មានកម្ពស់៦ម៉ែត្រ សង់ពីថ្មបាយក្រៀម និងថ្មភក់សម្រាប់ស៊ុមទ្វារ។ ប្រាង្គនេះមិនមានក្បាច់រចនាលើទេ។ យើងមិនប្រទះឃើញបំណែកហោជាង ផ្តែរ សសរស្តម្ភនៅក្នុងបរិវេណប្រាសាទទេ។ សូម្បីខ្លោងទ្វារនៃប្រាសាទក៏មិនមានក្បាច់លម្អណាមួយដែរ។

ទាក់ទងនឹងការពុកផុយនៃប្រាសាទ ជញ្ជាំងខាងជើងនៃប្រាង្គបានធ្លាក់បាក់រលំ ដុំថ្មបាយក្រៀមនៃប្រាង្គធ្លាក់គលើគ្នានៅជ្រុងខាងជើងនេះ។ តាមការសង្កេតពីសណ្ឋានដីជុំវិញប្រាសាទ យើងឃើញថា ប្រាសាទនេះសង់នៅលើដីធម្មជាតិ ដោយមិនមានលើកដីជាធ្លាទេ។ នៅភាគខាងជើងជិតប្រាសាទ ដីជម្រាលចុះ។ សណ្ឋានដីបែបនេះអាចប៉ះពាល់ដល់សំណង់ប្រាសាទ ពីព្រោះនៅពេលមានភ្លៀងធ្លាក់ ទឹកបាននាំដីហូរច្រោះទៅភាគខាងជើង។ ទឹកហូរពីទីខ្ពស់មកទាប គឺហូរពីប្រាង្គទៅភាគខាងជើង ធ្វើឲ្យដីហូរដាច់។ ដូច្នេះហើយបានជា កំពែងជ្រុងខាងជើង និងជញ្ជាំងប្រាង្គខាងជើងបាក់បែកខ្លាំង។



រូបលេខ១៦៖ ប្រាង្គកណ្តាលនៃប្រាសាទខាងជើង មើលពីទិសខាងកើត សង់ពីថ្មបាយក្រៀម




គំនូរប្លង់លេខ៦៖ រូបពំនុះកាត់អ័ក្សប្រាសាទខាងជើង

## ៣-ហោត្រៃ

ហោត្រៃជាអគារបុរាណនៅក្នុងបរិវេណប្រាសាទ ជាទូទៅបែរមុខបញ្ច្រាសទិសនឹងប្រាង្គកណ្ដាលនៃប្រាសាទ។ ហោត្រៃនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម និងមានថ្មភក់សង់សម្រាប់ស៊ុំទ្វារ។ ហោត្រៃនេះទំហំ៥ម៉ែត្រពីកើតទៅលិច និង៣ម៉ែត្រពីជើងទៅត្បូង។



រូបលេខ១៧៖ ហោត្រៃប្រាសាទខាងជើង


ប្លង់ប្រាសាទត្រពាំងប្រាសាទខាងជើង
៤២៩៩៥០
៤២៩៩៦០
៤២៩៩៧០
៤២៩៩៨០
៤២៩៩៩០
៤៣០០០០
៤៣០០១០
កំផែង
បរិវេនប្រាសាទ
គ្រឹះប្រាសាទ
ខ្លោងទ្វារ
បណ្ណាល័យ
សញ្ញាសំគាល់ :
កំផែង
តួប្រាសាទ
បរិវេនប្រាសាទ
បណ្ណាល័យ
ជ
មាត្រដ្ឋាន : ១ : ២៥០
០ ៥ ១០ ២០
ម៉ែត្រ
Coordinate System :
Projection : UTM
Spheroid : WGS84
Datum : WGS84
Zone : 48N
Unit : Meter

## ជំពូក៣៖ ការកំណត់អាយុកាលនៃប្រាសាទត្រពាំងប្រាសាទ

ការកំណត់អាយុកាលប្រាសាទ ជាទូទៅ យើងពឹងផ្អែកលើការសិក្សាវិធីសាស្ត្រប្រៀបធៀបទៅលើក្បាច់រចនាលើផ្តែរ ហោជាង សសរផ្តោប សសរស្តម្ភ បដិមា ឬសំលៀកបំពាក់នៃបដិមា។ ក្នុងករណីប្រាសាទមួយមានសិលាចារឹក នោះយើងអាចសិក្សាពីតួអក្សររបស់សិលាចារឹក និងការពិពណ៌នាអំពីព្រះមហាក្សត្រអង្គណាមួយ ហើយបើពុំនោះសោត សិលាចារឹកណាមួយមានចារពីកាលបរិច្ឆេទ នោះយើងអាចដឹងពីអាយុកាលប្រាសាទនោះតែម្តង។

យើងសូមលើកយកករណីប្រាសាទត្រពាំងប្រាសាទមកសិក្សា។ ការកំណត់អាយុកាលរបស់ប្រាសាទនេះ គឺទាមទារឱ្យមានការសិក្សាលើក្បាច់លម្អមានលើគ្រឿងស្ថាបត្យកម្មនៃប្រាសាទដែលបន្សល់នៅប្រាសាទដល់សព្វថ្ងៃ។ ចំពោះប្រាសាទនេះ យើងឃើញមានសំណល់លម្អក្បាច់តិចតួចបំផុត។ ទោះជាយ៉ាងណាយើងសាកល្បងសិក្សាអំពីអាយុកាលនៃប្រាសាទនេះ។

មុននឹងលើកអំពីការវិភាគទៅលើវត្ថុតាងផ្សេងៗនៅប្រាសាទ យើងបកស្រាយអំពីប្រវត្តិសាស្ត្រខ្លះ នៅសម័យអង្គរដែលទាក់ទងនឹងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ និងព្រះបាទរាជេន្ទ្រវរ្ម័នទី២។ យើងមានសម្មតិកម្មថា ព្រះបាទជ័យវរ្ម័នទី៤ បានប្តូររាជធានីចេញពីអង្គរមកកាន់កោះកេរ ហើយបានកសាងប្រាសាទធំៗនៅទីនោះ។ ដោយសារកោះកេរមានទីតាំងមិនឆ្ងាយប៉ុន្មានពីតំបន់ប្រាសាទត្រពាំងប្រាសាទ ដូច្នេះឥទ្ធិពលរបស់ព្រះអង្គអាចនឹងសាយភាយដល់តំបន់នេះ។ មួយវិញទៀត ក្រោយពីរាជរបស់ព្រះអង្គបន្តិច ព្រះបាទរាជេន្ទ្រវរ្ម័នក៏នៅបន្តយកឥទ្ធិពលសម័យកោះកេរមកប្រើទៀតនៅតាមតំបន់ខ្លះ។

មហាក្សត្រសំខាន់ៗនៅសតវត្សទី១០ បន្ទាប់ពីព្រះបាទយសោវរ្ម័ន មានព្រះបាទជ័យវរ្ម័នទី៤ រាជេន្ទ្រវរ្ម័នទី២ ជ័យវរ្ម័នទី៥ និងបន្ទាប់មកព្រះបាទសូរ្យវរ្ម័ន។ បុត្រាពីរអង្គរបស់ព្រះបាទយសោវរ្ម័ន និងបុត្រាមួយអង្គរបស់ព្រះបាទជ័យវរ្ម័នទី៤ គ្រងរាជ្យក្នុងរយៈពេលយ៉ាងខ្លី ហើយរាជព្រះអង្គពុំសូវសំខាន់ទេ។

ប្រវត្តិវិទូអឺរ៉ុបដំបូងដែលសិក្សាពីអង្គរបានចាត់ទុកការស្នងរាជ្យស្របច្បាប់ថា គឺជាការស្នងរាជ្យពីបិតាទៅបុត្រាច្បងដូចនៅអឺរ៉ុបដែរ ហើយពួកគេមានការភ្ញាក់ផ្អើលដែលព្រះរាជាច្រើនអង្គដែលឡើងសោយរាជ្យមិនមែនជាបុត្រាច្បងរបស់មហាក្សត្រទេ។ ហេតុនេះពួកគេនាំគ្នាគិតថា ព្រះរាជាទាំងនោះជាស្តេចជ្រែករាជ្យ។ ក្នុងចំណោមព្រះរាជាសំខាន់ៗដូចជា ព្រះបាទឥន្ទ្រវរ្ម័ន ជ័យវរ្ម័នទី៤ និងរាជេន្ទ្រវរ្ម័នទី២ ស្នងរាជ្យបន្តពីព្រះមហាក្សត្រដែលមិនមែនជាបិតា។ ក្រោយមកទាំងព្រះបាទជ័យវីរវរ្ម័ន និងសូរ្យវរ្ម័ន១ ដែលច្បាំងគ្នាដណ្តើមរាជ្យគឺជាក្សត្រនៅក្រៅរាជវង្សសំខាន់។

ដូច្នេះព្រះបាទជ័យវរ្ម័នទី៤ ស្នងរាជ្យព្រះបាទយសោវរ្ម័ន និងបុត្រាព្រះអង្គ ដូចគ្នានឹងការស្នងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៣-ឥន្ទ្រវរ្ម័ន។ ឯការស្នងរាជ្យរបស់ព្រះបាទរាជេន្ទ្រវរ្ម័នស្ថិតក្នុងករណីដូចគ្នា គឺជាការផ្ទេររាជបល្ល័ង្កវាងបងប្អូនប្រុស ឬរវាងសាច់ញាតិជាប់ខ្សែស្រឡាយមហាក្សត្រក្នុងជំនាន់ជាមួយគ្នា មុននឹងឆ្លងទៅជំនាន់មួយទៀតដែលជារាជ្យព្រះបាទជ័យវរ្ម័នទី៥។ រឿងរ៉ាវគ្រួសាររាជវង្សទាំងអស់អំពីព្រះបាទជ័យវរ្ម័នទី៤ បង្ហាញថា ព្រះអង្គជាក្សត្រមួយអង្គពេញសិទ្ធិក្នុងរាជវង្ស ហើយទ្រង់មិនមែនជាស្តេចជ្រែករាជ្យខុសច្បាប់ទេ។ មានរឿងតែមួយមិនច្បាស់គឺ អ្នកណាជាបិតារបស់ព្រះបាទជ័យវរ្ម័នទី៤ ដែលរឿងនេះអាចផ្តល់ជាតម្រុយចំពោះការសម្រេចចិត្តរបស់ព្រះបាទជ័យវរ្ម័នទី៤ ទៅកសាងរាជធានីនៅកោះកេរឆ្ងាយពីអង្គរ លើភ្នំឆោកគគ្យរ "ព្រៃគគីរ" ដែលសព្វថ្ងៃនេះហៅកោះកេរ ("កោះនៃកិត្តយស/កេរ្តិ៍ឈ្មោះ")។

**រចនាបទកោះកេរ (៩២១-៩៤៤)**

បូជនីយដ្ឋានកោះកេរ ស្ថិតនៅឆ្ងាយប្រមាណ១០០គីឡូម៉ែត្រខាងកើតពីក្រុងអង្គរ។ នៅទីនោះ ព្រះបាទជ័យវរ្ម័នទី៤បានកសាងប្រាសាទជាច្រើន ហើយតំកល់ព្រះសិវលិង្គដ៏ធំមួយដែលមានកំពស់ទៅដល់ ៤,៥ម៉ែត្រ ដើម្បីឧទ្ទិសដល់អាទិទេពត្រីភូវនេស្វរ។ ព្រះអង្គចូលទីវង្គត់នៅប្រហែលឆ្នាំ៩៤៤ ដោយមាន ព្រះនាមថា បរមសិវបទ។ សំណង់ប្រាសាទសំខាន់ៗក្នុងរចនាបទកោះកេរ រួមមាន ៖ ប្រាសាទក្រវ៉ាន់ (តំបន់អង្គរ) ប្រាសាទនាងខ្មៅ (ខេត្តតាកែវ) ចំណែកប្រាសាទនៅកោះកេរ ចែកជាបីក្រុម គឺ

១). នៅរហាល(ជាស្រះទឹកដែលគេជីក)ដែលមានទំហំ ៥៦០ ខ១,២០០ម៉ែត្រ និងប្រាសាទខាងជើង

២). ក្រុមប្រាសាទដែលបែរមុខទៅផ្នែកខាងកើតរបស់រហាល មាន៖ ប្រាសាទអណ្តូងគុក ប្រាសាទក្រចាប់ ប្រាសាទ បន្ទាយពាច័ន្ទ ប្រាសាទក្រហម។

៣). ក្រុមតួប៉មដែលរត់តាមអ័ក្សពីចុងខាងត្បូងរបស់រហាល មាន៖ ប្រាសាទចិន ប្រាសាទដំរី ប្រាសាទអង្គខ្នារ ប្រាសាទអណ្តូងប្រាសាទបាក់ ប្រាសាទនាងខ្មៅ និងប្រាសាទប្រាំ។

**លក្ខណៈទូទៅនៃស្ថាបត្យកម្ម**

ស្ថាបត្យកម្មនៃរចនាបទកោះកេរក៏មានលក្ខណៈអស្ចារ្យណាស់ដែរ គឺតួប្រាសាទធំៗ តួយ៉ាងដូចជា ប្រាសាទខាងជើង ដែលមានរាងដូចពីរ៉ាមីតមាន៧ថ្នាក់ កំពស់ដល់៣៥ម៉ែត្រ បែរមុខទៅខាងកើតនិងជណ្តើរមួយ។ មានសាលវែងៗដែលមានដំបូលធ្វើពីឈើ បន្ថែមចូលក្នុងប្លង់ប្រាសាទ។ ហើយបន្តប្រើប្រាស់ប្លង់។ ប៉ុន្តែការសាងសង់ ប្រាសាទគឺនៅលើដីរាប មិនមែនលើភ្នំដូចរចនាបថមុនទេ។ ការប្រើប្រាស់ឥដ្ឋក៏ដើរតួនាទីមួយសំខាន់ដែរ ដូចនឹង ថ្មភក់ដែរ ក្រៅពីនេះមានយកថ្មបាយក្រៀមធ្វើតួប៉មប្រាសាទតូចៗមួយចំនួន។ ការលេចឡើងនូវថែវតាមព័ទ្ធជុំវិញតួប៉មប្រាសាទ និងតួប៉មខ្ទះសង់ខ្វែងគ្នាដូចអង្គរវត្ត។

ផ្តែរទ្វារ ៖ មែកឈើកោងខ្លាំងទៅចំកណ្តាល ក្រោមទំងន់នៃក្បាច់ត្បូងដែលបង្ហាញរូបទេពជិះលើយានជំនិះ ឬជារឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងទេព ក្បាច់សសរដែលគេឃើញនៅសម្បូណ៌ព្រៃគុកបានបាត់បង់ជាលំដាប់។

សសរពេជ្រ ៖ មានក្បាច់រចនាច្រើនដូចមុនដែរ ជ្រុងនីមួយៗមានសន្លឹកមួយ និងពាក់កណ្តាលសន្លឹកពីរ នៅលើតួសសរ គេបន្ថែមកងច្រើនដែលមើទៅដូចថ្នាំងឫស្សី។

ហោជាង ៖ មានហោជាង៣ជ្រុងនិងកញ្ចុំជើងធ្នា ដែលមានការរចនាស្លឹកឈើសុទ្ធសាធ ឬមានរូបទេពនៅចំកណ្តាល។

បដិមា ៖ មានរូបរាងធំៗ មានលំនាំដូចបាខែងដែរ ប៉ុន្តែចាប់ផ្តើមរូបធ្វើចលនា (ឧទាហរណ៍ រូបអ្នកចំបាប់ពាលីសុគ្រីព រូបគ្រុឌ នៅសារមន្ទីរជាតិភ្នំពេញ។ រូបនាគ មានពាក់គ្រឿងអលង្ការដែលមានសណ្ឋានដូចស្នែង។ ម្យាងវិញទៀត មានរូបទោលជាច្រើនប្រកបដោយគ្រឿងអលង្ការ ៖ ខ្សែក ខ្សែដង ខ្លួនពីជាន់កងដៃ ស្នាប់កំភួនដៃនិងក្រវិល។ មានប្រើប្រាស់មកុដរាងជាសាជីច្រើនថ្នាក់ហើយមានក្បាច់លម្អច្រើន។

## រចនាបថប្រែរូប

រាជេន្ទ្រវរ្ម័នទី២ (៩៤៤-៩៦៨)

ដោយសារហេដ្ឋារចនាសម្ព័ននៅអង្គរមានលក្ខណៈល្អប្រសើរ គ្រាន់តែបានឡើងសោយរាជ្យភ្លាម ព្រះបាទរាជេន្ទ្រវរ្ម័ន បាននាំរាជធានីមកកន្លែងដើមវិញ ដោយបានជួសជុលប្រាសាទបក្សីចាំក្រុង និងតម្កល់ទេវរូប ធ្វើអំពីមាសព្រះនាមបរមស្វរៈ ព្រមទាំងចារសិលាចារឹកអំពីដើមកំនើតនៃជនជាតិកម្ពុជា។ ឯបរមរាជវាំងក៏តាំងទីជាអចិន្ត្រៃយ៍ចាប់ពីភាគចុងក្រោយនៃស.វទី១០មកយ៉ាងយូរណាស់ បន្ទាប់ពីរាជព្រះបាទរាជេន្ទ្រវរ្ម័នមកភ្លាម។ ព្រះរាជវាំងនេះបែរមកខាងកើតហើយសំឡឹងមើលចំមកមេបុណ្យ ព្រោះនៅចំអ័ក្សលិច-កើតជាមួយគ្នា។ បើពោលពីអ័ក្សជើង-ត្បូងវិញ គឺព្រះរាជវាំងសឹងតែធ្វើឡើងឱ្យមានន័យជានិមិត្តរូបផង ជាអាទិ៍គឺភ្ជាប់ទៅនឹងគ្រឹះ ទាំងឡាយនៃរាជធានីអង្គរ បារាយណ៍ខាងកើតព្រមទាំងភ្នំបាខែង។ ហេតុដូច្នេះហើយ បានជាលែងមានការផ្លាស់ប្តូររុះរើជាច្រើនសតវត្សតមក។ សំណង់ប្រាសាទសំខាន់ៗរួមមាន៖

-ប្រាសាទមេបុណ្យខាងកើត ឆ្នាំ៩៥២ នៅកណ្តាលបារាយណ៍យសោតដាក ប្រាសាទប្រែរូប៩៦១ ប្រាសាទលាក់នាងឆ្នាំ៩៦០ ប្រាសាទបាតជុំឆ្នាំ៩៥៣ (សាងដោយរាជគ្រូកវិន្ទ្ររីមថន) ស្រះស្រង់ មានទំហំ៧០០១៣៥០ម (សាងដោយរាជគ្រូកវិន្ទ្ររីមថន) គុតិស្វរ (រាជគ្រូកវិន្ទ្ររីមថន)។

តាមសិលាចារឹក មានការអភិសេកតំកល់ទេវរូបរាជេន្ទ្រស្វរ នៅថ្ងៃសុក្រទី២៨ ខែមករា ឆ្នាំ៩៥៣ ប្រាសាទមេបុណ្យខាងកើត ក្រោមការរៀបចំពិធីដោយរាជគ្រូកវិន្ទ្ររីមថន។ ឯប្រាសាទប្រែរូប មានឈ្មោះដើមថា "រាជេន្ទ្រភទ្រេស្វរ" ដោយយោងតាមឈ្មោះទេពបដិមាសំខាន់មួយនៅក្នុងតួប៉មកណ្តាលប្រាសាទ ឯផ្នែកខាងលើ ដែលមានតួប៉ម៤នៅជ្រុង ក៏មានតំកល់ទេវរូបព្រះឥសូរនៅឦសាន និងទេវរូបព្រះនារាយណ៍នៅអគ្នេយ៍ ឯតួប៉ម ខាងក្រោយតំកល់ទេវរូបមហេសី របស់ពួកគេគឺ ទេវរូបនាងលក្ស្មី និងឧមា។ ព្រះបាទរាជេន្ទ្រវរ្ម័នទី២ សុគតនៅក្នុងឆ្នាំ៩៦៨ ដោយមានមរណៈនាមសិវលោក។

### លក្ខណៈទូទៅនៃស្ថាបត្យកម្ម

ស្ថាបត្យកម្មបន្តនូវលក្ខណៈសំណង់ពីសម័យមុន ដែលរួមមាន៖

-ការត្រឡប់មកប្រើប្រាស់សំណង់ឥដ្ឋជាសមាសធាតុសំខាន់ក្នុងសំណង់ប្រាសាទ

-ប្រើប្រាស់កំបោរបាយអឡើងវិញ

-មានប្រាសាទភ្នំ និងប្រាសាទសង់លើខឿនរាបមួយជាន់

-បន្តសំណង់តួប៉មសំខាន់សង់ខ្វែងគ្នា

-មានសំណង់ប្រាសាទពុទ្ធសាសនា

-បន្តសំណង់បន្ទប់រាងវែង ប៉ុន្តែមានការវិវត្តិន៍ច្រើន

-បន្តសំណង់ខ្លោងទ្វារ ដោយមានគ្រប់ទិសទាំងបួន

-បន្តសំណង់ហោត្រៃ

-បន្តប្រើប្រាស់ប្លង់កណ្តាល

-បន្តសំណង់កំពែងព័ទ្ធជុំវិញ

## សមាសធាតុលម្អស្ថាបត្យកម្ម

ផ្តែរទ្វារ៖ ក្បាច់លម្អមានលក្ខណៈដូចរចនាបថមុន សារៈសំខាន់នៃក្បាច់ជួងនៅចំកណ្តាលមានធ្លាក់ជារឿង។ ការលេចឡើងវិញនៅគែមខាងក្រោមរបស់ផ្តែរ ប៉ុន្តែការតុបតែងពុំសូវសម្បូណ៌បែបទេ។

សសរពេជ្រ    មានលំនាំដូចរចនាបទកោះកេរ
បដិមា ៖ មានលក្ខណៈសង្ហារ មាឌធំ និងគ្មានចលនា និងទឹកមុខស្លូត។

## ការកំណត់អាយុប្រាសាទត្រពាំងប្រាសាទ

ប្រាសាទត្រពាំងប្រាសាទមិនមានសិលាចារឹក និងមិនមានគ្រឿងលម្អច្រើននោះទេ។ អ្វីដែលយើងអាចសិក្សាពីអាយុកាលរបស់ប្រាសាទខាងត្បូងនៃត្រពាំងប្រាសាទបានគឺផ្តែរនៃប្រាសាទខាងត្បូងតែមួយប៉ុណ្ណោះ។ ចំណែកការសិក្សាពីអាយុរបស់ប្រាសាទខាងជើងមិនអាចសិក្សាបានទេ ដោយសារមិនមានសិលាចារឹក ហើយក៏មិនមានហោជាង សសរពេជ្រ និងផ្តែរទេ។ ម៉្យាងទៀត ប្រាសាទនេះកសាងឡើងដោយមិនមានរចនាក្បាច់លម្អអ្វីទាំងអស់។ អាយុកាលដែលអាចកំណត់បានចំពោះប្រាសាទខាងជើង គឺស្ថិតក្នុងសម័យអង្គរ។ ហើយបើតាមគុណភាពថ្មភក់ ប្រាសាទខាងជើងប្រហែលអាចកសាងលឡើងក្នុងសតវត្សទី១៣ ស្ថិតនៅចុងសម័យអង្គរ។ នេះជាការសន្និដ្ឋានជំហានដំបូង។

ចំពោះប្រាសាទខាងត្បូង អាចសិក្សាពីងាយុកាលបានតាមរយៈផ្តែរពីរបំណែកក្នុងបរិវេណប្រាសាទ។ ផ្តែរពីរបំណែកនេះបែកចេញពីផ្តែរតែមួយ។ បំណែកទាំងពីរជាផ្នែកកណ្តាលនិងក្រោមនៃផ្តែរ។ បើយើងវិភាគទៅលើក្បាច់លម្អនៅលើផ្តែរ ផ្តែរនេះមានក្បាច់លម្អប្រហែលគ្នានឹងផ្តែររចនាបថកោះកេរ និងផ្តែររចនាបថប្រែរូប។

ប្លង់ប្រាសាទក៏ជាភស្តុតាងមួយអាចឲ្យយើងសិក្សាបានពីអាយុកាលដែរ។ ប្រាសាទខាងត្បូងសង់ឡើងដោយមានប្រាង្គបីលើទួលលើកខ្ពស់មួយ ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងកសិណទឹក។ កំពែងថ្មបាយក្រៀម មានខ្លោងទ្វារបួន ដែលខ្លោងទ្វារធំស្ថិតនៅខាងកើតដែលជាច្រកសំខាន់ជាងគេ។ ប្លង់ប្រាសាទបែបនេះ អាចដូចគ្នា នឹងប្លង់ប្រាសាទសង់ក្នុងរចនាបថប្រែរូប។

សរុបមក ការសន្និដ្ឋានឲ្យជាក់ច្បាស់ពីអាយុកាលនៃប្រាសាទខាងត្បូងមិនអាចធ្វើបានឡើយ។ ការសន្និដ្ឋានដំបូងពីអាយុកាលនៃប្រាសាទនេះ គឺប្រហែលក្នុងសតវត្សទី១០ ក្នុងរចនាបថកោះកេរ និងប្រែរូប។

ប្រាសាទត្រពាំងប្រាសាទខាងជើងមានរូបរាង និងប្លង់ដូចគ្នានឹងមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គបានកសាងនៅតាមផ្លូវបុរាណក្នុងរាជរបស់ព្រះអង្គ។ យើងអាចដឹងថា ប្រាសាទក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងសតវត្សទី១៣។ ដូច្នេះ ប្រាសាទត្រពាំងប្រាសាទខាងជើងប្រហែលជាសាងសង់ក្នុងសតវត្សទី១៣ ក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី៧។

## សន្និដ្ឋាន

ប្រាសាទត្រពាំងប្រាសាទជាប្រាសាទមួយមិនទាន់បានសិក្សានិងចុះបញ្ជីនៅឡើយ។ ទោះបីនៅសម័យមុនសង្គ្រាម អ្នកស្រាវជ្រាវជនជាតិបារាំងបានចុះសិក្សា និងចុះបញ្ជីប្រាសាទជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែ ប្រាសាទមួយនេះ ត្រូវមើលរំលង។ ទោះបីថា អ្នកស្រាវជ្រាវបារាំងមិនបានចុះសិក្សាស្រាវជ្រាវ និងចុះបញ្ជីក្តី ក៏នៅមិនទាន់មានការសិក្សាពីប្រាសាទនេះទៀត ហូតទាល់តែមន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជាសិក្សាស្រាវជ្រាវ ដោយទទួលការគាំទ្រថវិការពីរាជរដ្ឋាភិបាលកម្ពុជា និងមានការគាំទ្រពីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ ព្រមទាំងអជ្ញាធរដែនដី តាំងពីថ្នាក់ខេត្តរហូតដល់មូលដ្ឋានភូមិ ឃុំ និងស្រុក។

ប្រាសាទត្រពាំងប្រាសាទទាំងពីរទទួលរងការខូចខាតពីកត្តាធម្មជាតិ ដោយទទួលរងការទន្ទ្រានពីព្រៃឈើដុះពីលើ ទឹកភ្លៀងហូរច្រោះបំផ្លាញខឿនប្រាសាទ។ កត្តាបំផ្លាញប្រាសាទមួយទៀតគឺការបំផ្លាញរបស់មនុស្ស។ ប្រទេសកម្ពុជាអូសបន្លាយដោយសង្គ្រាមផ្ទៃក្នុងបានធ្វើឲ្យមានអំពើចោរកម្មទៅលើប្រាសាទបុរាណ ការជីកកកាយរកវត្ថុបុរាណនៅតាមផ្នូរបុរាណ ការជីកគាស់ទួលគ្រឹះប្រាសាទ និងអំពើលួចវត្ថុបុរាណផ្សេងៗទៀត។ សកម្មភាពបែបនេះក៏មានកើតឡើងនៅប្រាសាទត្រពាំងប្រាសាទដែរ។ ក្រុមចោរលួចវត្ថុបុរាណបានគាស់ និងជីករកវត្ថុបុរាណក្នុងបរិវេណប្រាសាទ ធ្វើឲ្យខឿនប្រាសាទជ្រុងអាគ្នេយ៍។ ប្រហែលត្រូវក្រុមចោរលួចគ្រឿងស្ថាបត្យកម្មនៃប្រាសាទ បានជាមិនមានក្នុងបរិវេណប្រាសាទ។

ការពុកផុយនៃប្រាសាទត្រពាំងប្រាសាទក៏រួមចំណែកកើតឡើងដោយសារបច្ចេកទេសសំណង់ដែរ។ តួប្រាសាទខាងជើង និងខាងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូងសង់លើខឿនប្រាសាទដែលខឿននោះមានទំហំតូច មិនអាចទ្រកម្លាំងសង្កត់របស់តួប្រាសាទបាន។ នៅពេលខឿនប្រាសាទសឹករិចរឹលដោយសារទឹកភ្លៀងហូរច្រោះ តួប្រាសាទទាំងលែងមានលំនឹង ហើយទ្រេតទៅតាមទិសដែលខឿនប្រាសាទខូច។ តួខាងត្បូងទ្រេតរកកលនឹងរលំទៅទិសខាងត្បូង រីឯតួខាងជើងទ្រេតទៅទិសខាងជើង។

ទាក់ទងនឹងអាយុកាលនៃប្រាសាទខាងត្បូង បើយើងមើលវិភាគទៅលើប្លង់នៃប្រាសាទ ប្រាសាទនេះគឺសង់ក្នុងរង្វង់រចនាបថកោះកេរ្តិ៍ ឬប្រែរូប ក្នុងសតវត្សទី១០ គឺក្នុងរាជព្រះបាទជ័យវរ្ម័នទី៤ និងព្រះបាទរាជេន្ទ្រវរ្ម័នទី២។ នៅពេលព្រះជ័យវរ្ម័នទី៤ ប្តូររាជធានីមករាជធានីកោះកេរ្តិ៍ ព្រះអង្គបានពង្រីកឧទ្ទិពលរបស់ព្រះអង្គទៅភាគខាងជើង ក្នុងគោលបំណងគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ភាគខាងជើង ជាពិសេសតំបន់ជួរភ្នំដងរែក។ ទោះបីព្រះបាទរាជេន្ទ្រវរ្ម័នទី២ប្តូររាជធានីមកក្រុងអង្គរក្តី ការរស់នៅរបស់មនុស្សដែលបន្តពីព្រះបាទជ័យវរ្ម័នទី៤ នៅតែមាន។ ចំណែកប្រាសាទត្រពាំងប្រាសាទខាងជើង ប្រហែលជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ កសាងក្នុងសតវត្សទី១៣។ ដោយសារភាពសម្បូណ៌បែបនៃធនធានធម្មជាតិនៅតំបន់ភាគខាងជើងជាពិសេសតំបន់ជួរភ្នំដងរែក ព្រះបាទជ័យវរ្ម័នទី៧ នៅបន្តគ្រប់គ្រងតំបន់ទៀត ដើម្បីប្រមូលផលពីធនធានធម្មជាតិពីតំបន់ខាងជើងនេះ។

ការសិក្សានិងរុករកស្ថានីយប្រាសាទបុរាណក្នុងតំបន់ស្រុកត្រពាំងប្រាសាទក្នុងពេលអនាគត នឹងជួយស្វែងរកទិន្នន័យផ្នែកបុរាណវត្ថុវិទ្យាជាច្រើនទៀតទាក់ទងនឹងតំបន់ខាងជើង ពិសេសគឺតំបន់ជួរភ្នំដងរែក។

## ឯកសារពិគ្រោះ

មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ,

២០០៥ "ការសិក្សាផ្ទៃលើស្ថានីយ និងការធ្វើផែនទីសារពើភ័ណ្ឌបុរាណវត្ថុ (ទួលបុរាណ) ក្នុងឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល" រាជបណ្ឌិត្យសភាកម្ពុជា។

កើត គឹមហៃ,

២០០៦ "ប្រាសាទស្លាប់" ក្នុងសន្និសីទជាតិស្តីពី "អភិរក្សនិងអភិវឌ្ឍវប្បធម៌-សិល្បៈខ្មែរ" លើកទី៣, រាជបណ្ឌិត្យសភាកម្ពុជា។

Etienne Aymonier,

1901 "Le Cambodge II Les Provinces Siamese", Paris.

Gilbert de Coral Rémusat,

1951 "L'Art Khmer Les grandes étapes de son évolution", Paris.

Lawrence Palmer Brigg,

1951 "The Ancient Khmer Empire" The American Philosophical Society, Independent Square Philadelphia 6.

Lunet De Lajonquière,

1907 "Inventaire Descriptive des Monuments du Cambodge", Tome dexième, Paris

National Committee for Sub-National Democratic Development (NCDD),

2009 "Trapeang Prasat District Data Book 2009" Otdor Meanchey Province.